## ឧបសម្ព័ន្ធទី ៨: វិធីសាស្ត្រក្នុងការជ្រើសរើសប្រភេទឈើសំរាប់ដាំដើម្បីកាត់បន្ថយភាពក្រីក្រ

ដើម្បីបំពេញតំរូវការរបស់កសិករក្នុងការជ្រើសរើសប្រភេទឈើសំរាប់ដាំ គេគួរប្រកាន់យកនូវវិធីសាស្ត្រមួយចំនួនដូចខាងក្រោម :

- o កំណត់ប្រភេទឈើដែលសហគមន៍ត្រូវការ
- o វាយតំលៃប្រភេទឈើដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន
- o ធ្វើចំណាត់ថ្នាក់នូវការប្រើប្រាស់សំខាន់ៗ ( ផលិតផល និងសេវាកម្ម)
- o កំណត់ប្រភេទឈើអាទិភាពមួយចំនួន
- o វាយតំលៃនិងធ្វើចំណាត់ថ្នាក់ប្រភេទឈើអាទិភាពបណ្តោះអាសន្នទាំងនោះ
- o ជ្រើសរើសប្រភេទឈើអាទិភាពសំរាប់ដាំ ។

### *ជ្រើសរើសប្រភេទឈើដែលមានតំលៃសេដ្ឋកិច្ចខ្ពស់:*

នាពេលបច្ចុប្បន្ននេះមាននិន្នាការនៃការប្រើប្រាស់ ប្រភេទឈើដែលមានតំលៃសេដ្ឋកិច្ចខ្ពស់ដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករ:

- o កសិករភាគច្រើនមិនប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិត ។ តំលៃបន្ថែមផ្សេងៗទៀតអាច ទាញចេញពីដើមឈើដោយផ្ទាល់ ។
- o ទីផ្សារសំរាប់ផលិតផលពីធម្មជាតិមានការកើនឡើងជាលំដាប់ ។
- o ទោះបីជាមិនមានតំលៃខ្ពស់នៅលើទីផ្សារក៏ដោយ ប្រភេទឈើដែលផ្តល់លច្រើនមុខនៅតែចាត់ទុកជាប្រយោជន៍ ។
- o ក្នុងការប្រាស្រ័យទាក់ទងជាមួយកសិករគេត្រូវចៀងចាំនូវពាក្យប្រុងប្រយ័ត្ន ។

មានវិធីសាស្ត្រផ្សេងៗជាច្រើនដើម្បីទទួលបាននូវប្រភេទឈើដែលមានតំលៃសេដ្ឋកិច្ចខ្ពស់:

- o បន្ថែមតំលៃទៅលើដើមឈើ (ដែលមានស្រាប់) និងផលិតផលដែលទាញចេញពីដើមឈើនោះ (បង្កើនគុណភាពដើមឈើដោយការក្រីមែក ការធ្វើឱ្យរបោល ការកែច្នៃនៅនឹងកសិដ្ឋាន ការដាំជួសដោយដើមឈើដែលមានគុណភាពល្អ ។
- o បន្តិចម្តងៗ ដាំជួសនូវដើមឈើដែលមិនសូវមានតំលៃ ដោយដើមឈើដែលមានតំលៃជាង
- o ដាំឈើចំរុះប្រភេទនៅក្នុងកសិដ្ឋានដើម្បីជៀសវាងនូវការប្រឈមនឹងគ្រោះថ្នាក់ផ្សេងៗ ។